ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ បឹងដីក្រហម

ភូមិ ៖ សៀមបោយ ព្រៃចារក្រៅ ព្រៃចារក្នុង បាទី ព្នៅលិច និងព្នៅកើត

ឃុំ ៖ ព្រៃចារ

ស្រុក ៖ ជើងព្រៃ

ខេត្ត ៖ កំពង់ចាម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | បឹងដីក្រហម |
| ភូមិ | ៖ | សៀមបោយ ព្រៃចារក្រៅ ព្រៃចារក្នុង បាទី ញ្ញៅលិច និងញ្ញៅកើត |
| ឃុំ | ៖ | ព្រៃចារ |
| ស្រុក | ៖ | ជើងព្រៃ |
| ខេត្ត | ៖ | កំពង់ចាម |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១. ស្ថានភាពទូទៅ** ............................................................ 1
**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ............................................................ 1
ក- ប្រជាសាស្ត្រ ............................................................ 1
ខ- មុខរបរ ............................................................ 2
**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុង កន្លែងនេសាទសហគមន៍** ............................................................ 2
ក- ទីតាំង ............................................................ 2
ខ- ដែននេសាទ ............................................................ 2
គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ............................................................ 3
ឃ- ធនធានជលផល ............................................................ 3
**៤. ការធ្វើនេសាទ** ............................................................ 3
ក- អ្នកនេសាទ ............................................................ 3
ខ- ឧបករណ៍នេសាទ ............................................................ 4
គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ............................................................ 5
**៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ** ............................................................ 5
ក- ទស្សនៈវិស័យ ............................................................ 5
ខ- គោលបំណង ............................................................ 6
គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............................................................ 6
គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ ............................................................ 6
គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ............................................................ 7
គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក ............................................................ 7
គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ............................................................ 8
គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ............................................................ 8
គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ............................................................ 9
គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ............................................................ 10
ឃ- ផែនការយុទ្ធសាស្ត្រ ............................................................ 12
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងដីក្រហម រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)** ............................................................ 13
**តារាងកម្មវិធីការងារ** ............................................................ 17

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទបឹងដីក្រហមបានរៀបចំមហាសន្និបាតកំណើតលើកដំបូង នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១២ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ។

សហគមន៍នេសាទបឹងដីក្រហមមានទីតាំងស្ថិតនៅក្នុងភូមិសៀមបោយ ព្រៃចារក្រៅ ព្រៃចារក្នុង បាទី ត្នោលិច និងត្នោកើត ឃុំព្រៃចារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មានសមាជិកសហគមន៍នេសាទសរុបចំនួន១០៥នាក់ មានប្រុសចំនួន៦៦ និងស្រីចំនួន៣៩នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន១០៥គ្រួសារ ដែលមានគណៈកម្មការសហគមន៍នេសាទចំនួន០៩នាក់ ស្រី០២នាក់ និងមានក្រុមល្បាតចំនួន០៥នាក់។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- រៀបចំធ្វើមហាសន្និបាតបង្កើតសហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ និងបង្កើតក្រុមល្បាត
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងធ្វើផែនទី
- រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ចុះល្បាត តាមដាន និងទប់ស្កាត់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ចូលរួមប្រជុំជាមួយអាជ្ញាធររដ្ឋបាលភូមិ ឃុំ
- ប្រមូលព័ត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក- ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន៨០៦៧នាក់ ប្រុស៣៧៧៦នាក់ ស្រី៤២៩១នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន៨០៥៤នាក់ ខ្មែរឥស្លាម០នាក់ និងអាណិកជនវៀតណាមចំនួន១៣នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៧៤នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ៦២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៩៥នាក់ ប្រុស៦១នាក់ ស្រី ៣៤នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៩៩នាក់ ប្រុស ៤៤នាក់ ស្រី ៥៥នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤២នាក់ ប្រុស ២២នាក់ ស្រី ២០នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍អ្នកកាន់សាសនាព្រះពុទ្ធ១០០%។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាម ប្រមាណ 0% សាសនាកាតុលិកប្រមាណ 0%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ មានអ្នកមិនចេះអក្សរចំនួន៧២៣នាក់ ស្រី៤៧៩នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១៩១៥នាក់ ស្រី១០១៥នាក់ និងកម្រិតមធ្យមសិក្សាចំនួន១៣២០នាក់ ស្រី៨៧៥នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាចំនួន៧៥នាក់ ស្រី៣០នាក់។

ខ- មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ៦០៥គ្រួសារ
- ធ្វើស្រែចំនួន ១០៥៥គ្រួសារ ទំហំផ្ទៃដី ៩៩០ហិកតា
- ធ្វើវារីវប្បកម្មចំនួន ២២៥គ្រួសារ ទំហំប្រហែល ១២ហិកតា
- ជាងផ្ទះចំនួន ១៤គ្រួសារ
- កម្មករចំនួន ២៤៥៤គ្រួសារ
- មន្ត្រីរាជការចំនួន ៥១គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ មានចំនួន ៨.២៥០.០០០រៀល។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក- ទីតាំង

កន្លែងនេសាទសហគមន៍បឹងដីក្រហម ជាដែននេសាទទឹកដែលបានកាត់ចេញពីឡូត៍នេសាទលេខ៣ នៃខេត្តកំពង់ចាម។

កន្លែងនេសាទសហគមន៍បឹងដីក្រហមមានទំហំ១០៣០ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹង ៖ ឃុំព្រៃចារ ស្រុកជើងព្រៃ និងផ្លូវជាតិលេខ៧
- ខាងត្បូងទល់នឹង ៖ ស្រុកកងមាស ខេត្តកំពង់ចាម
- ខាងកើតទល់នឹង ៖ ស្រុកព្រៃឈរ ខេត្តកំពង់ចាម
- ខាងលិចទល់នឹង ៖ ឃុំព្រៃចារ និងឃុំសូទិព្វ ស្រុកជើងព្រៃ និងផ្លូវជាតិលេខ៧

ខ- ដែននេសាទ

កន្លែងនេសាទសហគមន៍**បឹងដីក្រហម**មានបឹងចំនួន១និងទំនាបលិចទឹកក្នុងរដូវជំនោឡើងនិងនាទីព្រៃលិចទឹក៖

- បឹងឈ្មោះដីក្រហមមានប្រវែងបណ្តោយប្រហែល៣០០០ម៉ែត្រ និងទទឹងប្រហែល២៥០ម៉ែត្រ អាចធ្វើនេសាទពេញមួយឆ្នាំ
- ទំនាបលិចទឹកក្នុងរដូវជំឡើងនិងនាទីព្រៃលិចទឹកមានទំហំប្រហែល៩៥៥ហិកតា អាចធ្វើនេសាទពីខែសីហា ដល់រហូតខែវិច្ឆិកា ជារៀងរាល់ឆ្នាំ។

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អន្លង់ចង្ក្រានដែក មានទំហំ ៤,៥ហិកតា (បណ្តោយ ៣០០ម៉ែត្រ និងទទឹង ១៥០ម៉ែត្រ)។

ឃ- ធនធានជលផល

- ប្រភេទត្រី (ត្រីឆ្តោ ត្រីរ៉ស់ ត្រីឆ្លាំង ត្រីអណ្តែង ត្រីដំរី ត្រីឆ្លូញ ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីកែស ត្រីប្រា ត្រីពោ ត្រីក្រម៉ម ត្រីតាអោន ត្រីក្អែក ត្រីក្រឡង់ ត្រីសណ្តាយ ត្រីកញ្ជនជ័យ ត្រីខ្នាន់ ត្រីឈ្មៀត ត្រីក្រាញ់ ត្រីចង្វា ត្រីផ្ទោង ត្រីអាចម៍កុក ត្រីកញ្ជ្រូក ត្រីបណ្តូលអំពៅ ត្រីប្រកែង ត្រីកាហែ ត្រីក្រាយ ត្រីខ្ទឹង ត្រីព្រួល ត្រីទ្រនេន ត្រីត្រសក់ ត្រីគល់រាំង ត្រីកន្ត្រប ត្រីកន្ត្របខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីស្លឹកឬស្សី ត្រីក្លាំងហាយ ត្រីកន្ធរ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស់ ត្រីកំភ្លាញ កំពឹស បង្កង,.....។ល។)
- ប្រភេទវារីសត្វ (ពស់ ខ្ចៅ លៀស គ្រំប៉ោក ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) គ្រំចំពុះទា ក្តាម អន្ទង់ កង្កែប អណ្តើក កន្ធាយ ភេ,......។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (ដើមរាំង ភ្នំភ្លើង អញ្ចាញ កន្សែង ស្នែងក្របី ស្នូលទឹក ច្រកែង ប្រផែញ ផ្តៅ ប្របួយមេ ប្របួយឈ្មោល ថ្លើមអណ្តើក អូយយ៉ាស់(បន្លាយយួន) ភ្នែកព្រាប ព្រលិតដូង រំចង់ ស្គន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខ្មៅ ចំប្លង កក់ជ្រុង កក់ក្តាម ឈូក បាក់ដង កន្សៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្ងាង ត្នួ ខ្នាយមាន់ វល្លិប្រេង វល្លិទឹកដោះ វល្លិត្រដិត វល្លិដោះគន់ វល្លិត្រី វល្លិត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហែ វញ្ញា ស្នោ ស្លត់ បន្លាឃ្លេ ផ្ទោល ថ្ងាន់ ត្រដក់ កន្ទុយអន្ទង់ ពោះក្អម ត្រកួន ព្រលិតអាចមន៍មាន់ ចន្ទល់ភ្នំ(វល្លិថ្កាល់ត្រី) កញ្ជែត ស្មៅថ្នក់ទឹក ស្គន់ដំរី វល្លិអណ្តាតត្រកួត ក្រចាប់ កំពីងពួយស កំពីងពួយក្រហម សារាយ កំប្លោក ចកតូច ចកធំ ។ល។)

## ៤. ការធ្វើនេសាទ

ក- អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១០៥នាក់ ស្រី៣៨នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៥០០នាក់ ស្រី២០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន២៥០នាក់ ស្រី១២នាក់

ខ- ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូករបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៥០ | ១៥០ម-២០០ម/គ្រួសារ | ១០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួន | ម៉ែត្រ | ១០ | ៣០ម៉ែត្រ/គ្រួសារ | ៣០០ម៉ែត្រ | ខែធ្នូ-ខែឧសភា |
| សន្ទូចរនង | ផ្លែ | ១០ | ២០០-៣០០ផ្លែ / គ្រួសារ | ៣០០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លបត្រីរស់ | គ្រឿង | ៨ | ១៥-២៥គ្រឿង/គ្រួសារ | ២០០គ្រឿង | ខែវិច្ឆិកា-ខែឧសភា |
| លាន់ | គ្រឿង | ២៥ | ២៥គ្រឿង/គ្រួសារ | ៦៥០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ៣ | ១០គ្រឿង/គ្រួសារ | ៣០គ្រឿង | ខែមិថុនា-ខែសីហា |
| សំណាញ់ | វង់ | ៦០ | ១វង់/គ្រួសារ | ៦០វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១០៥គ្រឿង | ២០០-១០០០គីឡូក្រាម | ៦,៥-១៨សេះ |
| ទូកអុំ និងចែវ | គ្មាន | | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០០ | ១៥០ម-៤០០ម/គ្រួសារ | ៨០០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួន | ម៉ែត្រ | ២០ | ៣០-៥០ម៉ែត្រ/គ្រួសារ | ៦០០ម៉ែត្រ | ខែធ្នូ-ខែឧសភា |
| សន្ទូចរនង | ផ្លែ | ៥០ | ២០០-៥០០ផ្លែ / គ្រួសារ | ២៥០០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លបត្រីរស់ | គ្រឿង | ៣០ | ១៥-២៥គ្រឿង/គ្រួសារ | ៧៥០គ្រឿង | ខែវិច្ឆិកា-ខែឧសភា |
| លាន់ | គ្រឿង | ២០ | ២៥គ្រឿង/គ្រួសារ | ៥០០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ១០ | ១០គ្រឿង/គ្រួសារ | ១០០គ្រឿង | ខែមិថុនា-ខែសីហា |
| សំណាញ់ | វង់ | ១០០ | ១វង់/គ្រួសារ | ១០០វង់ | ពេញមួយឆ្នាំ |
| ឈ្នាងជញ្ជាត់លៀស | គ្រឿង | ៤៥ | ១គ្រឿង/គ្រួសារ | ៤៥គ្រឿង | ខែធ្នូ-ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០០គ្រឿង | ២០០-១០០០គីឡូក្រាម | ៦,៥-១៨សេះ |
| ទូកអ៊ុំ និងចែវ | គ្មាន | | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២២០ | ១៥០ម-៤០០ម/គ្រួសារ | ៨៨០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួន | ម៉ែត្រ | ១៥ | ៣០-៥០ម៉ែត្រ/គ្រួសារ | ៧៥០ម៉ែត្រ | ខែធ្នូ-ខែឧសភា |
| សន្ទូចរនង | ផ្លែ | ២០ | ២០០-៥០០ផ្លែ / គ្រួសារ | ១០០០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លបត្រីរស់ | គ្រឿង | ២៥ | ១៥-២៥គ្រឿង/គ្រួសារ | ៦២៥គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២០ | ១វង់/គ្រួសារ | ២០វង់ | ពេញមួយឆ្នាំ |
| ឈ្នាងលៀសអូសដោយទូកម៉ាស៊ីន | គ្រឿង | ៨ | ១គ្រឿង/គ្រួសារ | ៨គ្រឿង | ខែវិច្ឆិកា-ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២០០គ្រឿង | ២០០-១០០០គីឡូក្រាម | ៦,៥-១៨សេះ |
| ទូកអ៊ុំ និងចែវ | គ្មាន | | |

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១០០០គីឡូក្រាម | ៨០០គីឡូក្រាម | ១៨០០គីឡូក្រាម |
| ភាវីសត្វ (ខ្យង លៀស) | ៤៥០គីឡូក្រាម | គ្មាន | ៤៥០គីឡូក្រាម |

## ៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក- ទស្សនៈវិស័យ

សហគមន៍នេសាទ**បឹងដីក្រហម**មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ- គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានកាត់ចេញពីឡូត៍នេសាទលេខ៣នៅក្នុងខេត្តកំពង់ចាម ដោយរក្សាទុកសម្រាប់ឲ្យសមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋទូទៅធ្វើនេសាទស្របតាមបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទ ហើយថែរក្សាការពារទំនាបលិចទឹកក្នុងរដូវជំនោរ និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់សមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួមជាសហគមន៍នេសាទ
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ប្រភេទឧបករណ៍អនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ១.បឹងដីក្រហម | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ២០០០០ម៉ែត្រ/ ១០០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ១០៥០០ម៉ែត្រ/ ៧០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | អួន | ៣០ម/គ្រួសារ | ២៥០ម៉ែត្រ/ ១៥គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លបត្រីរស់ | ២០គ្រឿង/គ្រួសារ | ៨០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ២៥គ្រឿង/គ្រួសារ | ៨០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-សីហា | ទ្រូ | ១៥០ផ្លែ/គ្រួសារ | ២៥គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | ២៥០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | ឈ្នាងជញ្ជាត់លៀស | ១គ្រឿង/គ្រួសារ | ៤០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |

គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ចង្រ្កានដែក | ៤,៥ហិកតា (ប=៣០០មx ទ=១៥០ម) | អភិរក្សត្រីមេពូជ | បោះបង្គោលស៊ីម៉ងត៍ (7mX0.15mx0.15m) ចំនួន45ដើម ព័ទ្ធជុំវិញកន្លែងអភិរក្សត្រីមេពូជ ដែលមានបរិមាត្រ 900ម៉ែត្រ ក្នុងចន្លោះ 20ម៉ែត្រ បោះមួយបង្គោល។ | ៤៥០០ | ១/៣/១៩ | ១/៥/២០ |
| | | | ធ្វើស្លាកសញ្ញាអភិរក្ស ចំនួន៦ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | ៦០០ | ១/៤/១៩ | ១/៦/២០ |
| | | | ទម្លាក់គល់ឈើចំនួន ៣០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | ៤៥០០ | ១/៣/១៩ | ១/៥/២០ |
| | | | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | ១៥០០ | ១/៥/១៩ | ១/៧/២០ |

គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះ/ទីតាំង | ទំហំ (ហ.ត) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| នាទីព្រៃលិចទឹកនៅតាមបណ្តោយមាត់បឹងដីក្រហម | ២ | ដើមរាំង រំដេញ សណ្តាន់ ត្រស់ ប្របួយ ភ្នំភ្លើង | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹក ដែលត្រូវដាំ និងការពារ អភិរក្ស | ១៥០០ | ១/២/១៩ | ២០២១ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ធ្វើទិវាដាំព្រៃលិចទឹក ចំនួន៥០០០ដើម | ៤០០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើស្លាកសញ្ញាអភិរក្ស ចំនួន៤ផ្ទាំង សម្រាប់ ការពារព្រៃលិចទឹក | ៣០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើទិវាអភិរក្ស ដើម្បី ផ្សព្វផ្សាយអំពីគុណ តម្លៃ និងការគ្រប់គ្រង ព្រៃលិចទឹក | ៧០០ | ១/២/១៩ | ២០២១ |

## គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើង ដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួនគ្រួសារ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងស្រះ | ១០០ | ត្រីប្រា | ៦០០០០០កូនត្រី | ១/២/២០១៩ | ១/៦/២០២០ |
| ចិញ្ចឹមត្រីក្នុងស្រះ | ១០០ | ត្រីទីឡាព្យាក្រហម | ២៥៥០០០កូនត្រី | ១/៣/២០១៩ | ១/៦/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | ត្រីអណ្តែង | ២៨០០០កូនត្រី | ១/៤/២០១៩ | ១/៦/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ១០០ | កង្កែប | ៨០០០០កូនកង្កែប | ១/៤/២០១៩ | ១/៩/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | អន្ទង់ | ២៨០០០កូនអន្ទង់ | ១/១/២០១៩ | ១/១០/២០២០ |

## គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកស.ន<br>-រៀបចំបញ្ជីគណនេយ្យ<br>-ប្រមូលប្រាក់ភាគទានសុំចូលជាសមាជិកស.នចាស់ និងអ្នកសុំចូលជាសមាជិកថ្មី | ១/១/១៩ | ១/១/២១ | ១២៥ | ១០០០៛/១នាក់ សមាជិកចាស់/ថ្មី អាច៥០០នាក់ រយៈពេល៣ឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីការបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ | ១/១/១៩ | ១/១/២១ | ១៥០០ | -២០០០០៛ ៖សមាជិកធ្វើនេសាទជាអាជីព<br>-៥០០០៛ ៖សមាជិកធ្វើនេសាទម្តងម្កាល<br>-១០០០៛ ៖ ចំពោះសមាជិកគាំទ្រមិនធ្វើនេសាទ<br>-...៛? ៖ មិនមែនជាសមាជិកស.នតែធ្វើនេសាទជាអាជីព |
| -ជំនួយសប្បុរសជន<br>-អង្គការនានា<br>-ជំនួយរាជរដ្ឋាភិបាល | -រៀបចំសរសេរគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការស.នសុំដាក់បញ្ចូលសមាហរកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ១/១/១៩ | ១/១/២១ | ៤៣៦៥០ | ១៤៥៥០ដុល្លារ/ឆ្នាំ |
| | | | គម្រោងថវិកាសរុប | ៤៥២៧៥ $ | រយៈពេល៣ឆ្នាំ |

គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល

ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | គោលបំណង | អ្នកចូលរួមអនុវត្តន៍ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្នាច់០២គ្រឿង ប្រវែង៨ម៉ែត្រ និងម៉ាស៊ីនទូកកម្លាំង១៨សេះ | ចុះល្បាតការពារនិងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ២៥០០ | ២០១៩ | ២០២១ |
| ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត( អាវពោងសុវត្ថិភាព អាគុយ អំពូលភ្លើងហ្វា ទូរស័ព្ទ វិទ្យុទាក់ទង ម៉ាស៊ីនថត ពិល អាវភ្លៀង កែវយឺត មេក្រូ ប្រេង. | ប្រើប្រាស់សម្រាប់ចុះល្បាត តាមដាន ត្រួតពិនិត្យ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ១៥០០ | ២០១៩ | ២០២១ |
| រៀបចំក្រុមល្បាត និងបែងចែកតាមវេនចុះល្បាតប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ | ឲ្យមានក្រុម និងវេនចុះល្បាតឲ្យបានទៀងទាត់ជាប្រចាំ | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ៧០០ | ២០១៩ | ២០២១ |
| -ផ្សព្វផ្សាយតាមមេក្រូ៦ដង/ឆ្នាំ<br>-បិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយចំនួន២ដង/ឆ្នាំ | បង្កើនការយល់ដឹងអំពីការការពារកន្លែងអភិរក្សត្រីមេពូជ និងការចូលរួមទប់ស្កាត់បទល្មើស | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន<br>- អាជ្ញាធរភូមិ ឃុំ | ៣០០ | ២០១៩ | ២០២១ |

គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| វគ្គបណ្តុះបណ្តាល និងទិវាអភិរក្ស | គោលបំណង | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ក. វគ្គបណ្តុះបណ្តាល | | | | |
| ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងស.ន | បង្កើនយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលជលផល | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ជំនាញសម្របសម្រួល និងជំនាញដោះស្រាយទំនាស់ | មានចំណេះដឹងក្លាយជាអ្នកសម្របសម្រួល និងចេះដោះស្រាយទំនាស់បានល្អ | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបសរសេរលិខិតរដ្ឋបាល(របាយការណ៍ និងកំណត់ហេតុ) | មានចំណេះដឹងអំពីវិធីសរសេរ និងគ្រប់គ្រងលិខិតរដ្ឋបាល | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើផែនការអនុវត្តន៍សកម្មភាពគម្រោង | មានចំណេះដឹងអំពីរបៀបធ្វើផែនការសហគមន៍ និងផែនអនុវត្តន៍សកម្មភាពគម្រោង | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបសរសេរគម្រោងស្នើសុំថវិកា និងធ្វើផែនការគ្រប់គ្រងថវិកាស.ន និងរបៀបស្វែងរកថវិកា | មានចំណេះដឹងអំពីរបៀបសរសេរគម្រោងស្នើសុំថវិកា និងការធ្វើផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រស្វែងរកថវិកា | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| - កសាងភាពជាដៃគូ និងបណ្តាញ<br>- ភាពជាអ្នកដឹកនាំ | -មានចំណេះដឹងអំពីសារៈប្រយោជន៍កសាងភាពជាដៃគូ និងបណ្តាញ<br>-ក្លាយទៅជាអ្នកដឹកនាំសហគមន៍នេសាទដ៏ល្អ | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ប្រភេទនៃអ្នកចូលរួមក្នុងការអភិវឌ្ឍ | មានចំណេះដឹងអំពីការជ្រើសរើស និងធ្វើការជាមួយអ្នកចូលរួមពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |

| ខ. ទិវាអភិរក្ស និងផ្សព្វផ្សាយ | | | | |
|---|---|---|---|---|
| ការបង្កើត និងសារប្រយោជន៍នៃការគ្រប់គ្រងកន្លែងអភិរក្សត្រីមេពូជ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីការបង្កើត និងសារៈប្រយោជន៍នៃកន្លែងអភិរក្ស | -គណកម្មការស.ន<br>-សមាជិកសហគមន៍នេសាទ<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ ប្រជាពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| គុណតម្លៃនៃព្រៃលិចទឹក និង និងការគ្រប់គ្រងព្រៃលិចទឹក | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | -គណកម្មការស.ន<br>-សមាជិកសហគមន៍នេសាទ<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| ការធ្វើនេសាទប្រកបដោយនិរន្តរភាពក្នុងកន្លែងនេសាទសហគមន៍ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីការធ្វើនេសាទប្រកបដោយនិរន្តរភាព | -គណកម្មការស.ន<br>-សមាជិកសហគមន៍ស.ន<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋមូលដ្ឋាន | ២០១៩ | ២០២១ |
| ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | -គណកម្មការ<br>-សមាជិកសហគមន៍ស.ន<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋមូលដ្ឋាន | ២០១៩ | ២០២១ |

យ- ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហកមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារបឹង ការកំណត់ឧបករណ៏នេសាទ ការចិញ្ចឹមត្រី និងការរកស្វែងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពចំណេះដឹង បច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងដីក្រហម រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំពិគ្រោះយោបល់អំពីការប្រើប្រាស់ឧបករណ៍នេសាទឲ្យសមស្រប និងកំណត់ទីកន្លែងនេសាទឲ្យបានច្បាស់លាស់ | -ធ្វើនេសាទប្រកបដោយនិរន្តរភាព<br>-បង្កើនប្រាក់ចំណូលពីផលនេសាទ<br>-ធនធានជលផលកើនឡើង | ៣០០០ | -សមាជិកសហគមន៍ និងគណកម្មការស.ន<br>-អាជ្ញាធររដ្ឋបាលឃុំ | ២០១៩ | ២០២១ | |
| គ២-ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | បោះបង្គោលស៊ីម៉ងត៍ចំនួន45ដើមដាក់ព័ទ្ធជុំវិញកន្លែងអភិរក្សទំហំ4.5ហិកតា(300មX150ម) បោះបង្គោលស៊ីម៉ងត៍ក្នុងចន្លោះ 20ម៉ែត្រ បោះមួយបង្គោល។ | -មានព្រំប្រទល់កន្លែងអភិរក្សត្រីមេពូជ<br>-បែងចែកបានច្បាស់លាស់រវាងកន្លែងនេសាទ និងកន្លែងអភិរក្សត្រីមេពូជ | ៤៥០០ | -រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ១/៣/១៩ | ១/៥/២០ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៦ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | មានសញ្ញាសម្គាល់អំពីហាមឃាត់ចូលធ្វើនេសាទ និងហាមបើកបរទូកឆ្លងកាត់ខាងក្នុងកន្លែងអភិរក្សត្រីមេពូជ | ៦០០ | | ១/៤/១៩ | ១/៦/២០ | |
| | ទម្លាក់គល់ឈើចំនួន ៣០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | មានជម្រកសប្បនិម្មិតត្រីមេពូជ សម្រាប់រស់នៅធំលូតលាស់បន្តពូជពងកូន និងការពារមិនឲ្យលួចនេសាទ | ៤៥០០ | | ១/៣/១៩ | ១/៥/២០ | |
| | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារ | មានស្នាក់ការបណ្តែតទឹកសម្រាប់យាមល្បាត ការពារមិនឲ្យចូលនេសាទក្នុង | ១៥០០ | | ១/៥/១៩ | ១/៧/២០ | |

| | | | | | | |
|---|---|---|---|---|---|---|
| | កន្លែងអភិរក្សត្រីមេពូជ | កន្លែងអភិរក្សត្រីមេពូជ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ | | | | |
| គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹកដែលត្រូវដាំ និងការពារអភិរក្សព្រៃលិចទឹកនៅតាមបណ្តោយមាត់បឹងដីក្រហម | មានព្រំប្រទល់កន្លែងអភិរក្សព្រៃលិចទឹកច្បាស់លាស់ | ១៥០០ | | ១/២/១៩ | ២០២១ |
| | ធ្វើទិវាដាំព្រៃលិចទឹកចំនួន៥០០០ដើម | ត្រូវបានដាំកូនដើមព្រៃលិចទឹក(រាំងរំដេញ សណ្តាន់ គ្រស់ ប្របួយ ភ្នំភ្លេង) ក្នុងនៅទំហំដីលិចទឹក២ហិកនៅតាមបណ្តោយមាត់បឹងដីក្រហម | ៤០០០ | | ១/៣/១៩ | ២០២១ |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងសម្រាប់ការពារ អភិរក្សព្រៃលិចទឹកនៅតាមបណ្តោយមាត់បឹងដីក្រហម | មានសញ្ញាហាមឃាត់ការកាប់ទន្ទ្រានឈូសឆាយបំផ្លាញនាទីព្រៃលិចទឹក | ៣០០ | | ១/៣/១៩ | ២០២១ |
| | ធ្វើទិវាអភិរក្សដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីគុណតម្លៃនៃព្រៃលិចទឹក និងចូលរួមយ៉ាងសកម្មការពារ អភិរក្សព្រៃលិចទឹក។ | ៧០០ | | ១/២/១៩ | ២០២១ |
| គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈពាណិជ្ជកម្មនៅក្នុងបែ ស្រះ និងនិងតង់កៅស៊ូ។ | សមាជិកសហគមន៍នេសាទចំនួនប្រហែល១៥០គ្រួសារមានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈពាណិជ្ជ-កម្មនៅក្នុងបែ ស្រះ និងតង់កៅស៊ូ។ | ១៥០០០ | | ១/៥/១៩ | ១/៥/២១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍<br>-ប្រមូលការបង់ប្រាក់ភាគទានសុំចូលជាសមាជិក ស.ន និងអ្នកសុំចូលថ្មី<br>-ធ្វើគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការគ្រប់គ្រងកន្លែងនេសាទស.ន សម្រាប់សុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ទទួលបានថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍តាមគម្រោងផែនការ | ៤៥២៧៥ | -សមាជិក និងមិនមែនសមាជិកសហគមន៍ស:ន<br>-រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ១/១/១៩ | ១/១/២១ | |
| គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | -ទិញទូកស្ទាច់០២គ្រឿង ប្រវែង៨ម៉ែត្រនិងម៉ាស៊ីនទូកមានកម្លាំង១៨សេះ<br>-ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត<br>-រៀបចំក្រុមល្បាត និងបែងចែកវេនចុះល្បាត<br>-ផ្សព្វផ្សាយតាមមេក្រូ៦ដងក្នុងមួយឆ្នាំ និងបិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយ២ដងក្នុងមួយឆ្នាំ | -មានទូកម៉ាស៊ីន និងឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត ទប់ស្កាត់បទល្មើស<br>-ប្រជានេសាទទូទៅ និងសមាជិកសហគមន៍នេសាទបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់នៅក្នុងកន្លែងសហគមន៍នេសាទ និងបទល្មើសនេសាទថយចុះ | ៥០០០ | -រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -បណ្តុះបណ្តាលអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគមន៍នេសាទ និងពង្រឹងសមត្ថភាពគណៈកម្មការ និងសមាជិកស.ន។<br>-ធ្វើទិវាអភិរក្ស និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ និងលេង ល្បែងប្រាជ្ញា ដែលទាក់ទងកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងស.ន។ | - គណៈកម្មការ និងសមាជិកសហគមន៍បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហគមន៍នេសាទ និងមានសមត្ថភាពក្លាយជាអ្នកដឹកនាំល្អ ឬជាគ្រូបង្គោលក្នុងសហគមន៍មូលដ្ឋាន<br>- សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីសារប្រយោជន៍នៃកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ។ | ៣០០០ | -រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | ២០២១ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | → |
| គ២- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | ── | ── | ── | ── | → | | | | | | → | | | | | |
| គ៣- ផែនការគ្រប់គ្រងព្រៃលិចទឹក | | ── | ── | ── | ── | → | | | | | | | ── | → | | ── | → | |
| គ៤- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ── | ── | ── | ── | ── | ── | ── | ── | ── | → | - - | - - | - - | - - | - - | - - | → | - - → |
| គ៥- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | → |
| គ៦- ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | → |
| គ៧- ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | ── | → |

សូមគោរពជូន
លោកមេឃុំព្រៃចារ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមបោយ ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ២០១៨
ប្រធានគណៈកម្មការសហគមន៍នេសាទបឹងដីក្រហម

លេខ : [illegible]
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកងមាស
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ព្រៃលិច ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ២០១៨
មេឃុំព្រៃចារ

ឃុំព្រៃចារ

ស៊ឹម_ស៊ីយ

បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ចាម ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ២០១៨
នាយផ្នែករដ្ឋបាលជលផលកងមាស

លេខ : ១៧៤ វ.ស....

<u>បានឃើញ និងឯកភាព</u>

ថ្ងៃ............ ខែ...... ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២...

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

លេខ : ...........

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ............ ខែ...... ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២.

កំពង់ចាម ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

**គីម_សាឡឿន**

លេខ : ...........

បានឃើញ និងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់

និងនេសាទខេត្តកំពង់ចាម

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ...... ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦.....

កំពង់ចាម ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨

នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

**អ៊ុក_ណារិន**